ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ០១៨/១៩........ប.ស.ស

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ឲ្យចូលបម្រើការងារ នៅបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ឆ្នាំ២០១៩

បេឡាជាតិរបបសន្តិសុខសង្គម ហៅកាត់ ប.ស.ស គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានបេសកកម្មបម្រើឲ្យវិស័យសន្តិសុខសង្គម ដែលបច្ចុប្បន្នកំពុងដំណើរការរបបធានារ៉ាប់រងហានិភ័យការងារ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។ គ្រឹះស្ថាន ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា **ចំនួន ២៣១នាក់** ឲ្យបម្រើការងារនៅស្នាក់ការកណ្តាល និងបណ្តាសាខា ប.ស.ស ខេត្ត/ខណ្ឌ។ បេក្ខជនទាំងពីរភេទ (ជនពិការត្រូវបានលើកទឹកចិត្ត) ត្រូវមានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៤០ឆ្នាំ គិតមកដល់ថ្ងៃឈប់ទទួលពាក្យ និងពុំមានឈ្មោះបម្រើការងារក្នុងក្របខណ្ឌរដ្ឋ។

### ១ -លក្ខខណ្ឌនៃការជ្រើសរើស

**១)- ផ្នែកវេជ្ជបណ្ឌិត (ពិនិត្យឯកសារវេជ្ជសាស្ត្រ) សរុបចំនួន ៣០ នាក់**

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ផ្នែកវេជ្ជសាស្ត្រទូទៅឡើងទៅ
- អាចប្រើប្រាស់កម្មវិធី Ms. Word និង Ms. Excel បានល្អ
- មានភាពអំណត់ ស្មោះត្រង់ និងទំនួលខុសត្រូវខ្ពស់

**២)- ផ្នែកគិលានុបដ្ឋាក (ជំនួយការពិនិត្យឯកសារវេជ្ជសាស្ត្រ) សរុបចំនួន ៨៣ នាក់**

***បម្រើការងារតាមទីតាំងខាងក្រោម៖**

| | | | |
|---|---|---|---|
| ១. ស្នាក់ការកណ្តាល | ចំនួន ៤០ នាក់ | ១៤. សាខាខេត្តឧត្តរមានជ័យ | ចំនួន ០២ នាក់ |
| ២. សាខាខេត្តកណ្តាល | ចំនួន ០២ នាក់ | ១៥. សាខាខេត្តបន្ទាយមានជ័យ | ចំនួន ០២ នាក់ |
| ៣. សាខាខេត្តកំពង់ស្ពឺ | ចំនួន ០១ នាក់ | ១៦. សាខាខេត្តប៉ៃលិន | ចំនួន ០២ នាក់ |
| ៤. សាខាខេត្តព្រះសីហនុ | ចំនួន ០១ នាក់ | ១៧. សាខាខេត្តបាត់ដំបង | ចំនួន ០២ នាក់ |
| ៥. សាខាខេត្តកោះកុង | ចំនួន ០១ នាក់ | ១៨. សាខាខេត្តពោធិ៍សាត់ | ចំនួន ០២ នាក់ |
| ៦. សាខាខេត្តកែប | ចំនួន ០២ នាក់ | ១៩. សាខាខេត្តកំពង់ឆ្នាំង | ចំនួន ០២ នាក់ |
| ៧. សាខាខេត្តកំពត | ចំនួន ០២ នាក់ | ២០. សាខាខេត្តត្បូងឃ្មុំ | ចំនួន ០១ នាក់ |
| ៨. សាខាខេត្តតាកែវ | ចំនួន ០២ នាក់ | ២១. សាខាខេត្តក្រចេះ | ចំនួន ០២ នាក់ |
| ៩. សាខាខេត្តព្រៃវែង | ចំនួន ០២ នាក់ | ២២. សាខាខេត្តស្ទឹងត្រែង | ចំនួន ០២ នាក់ |
| ១០. សាខាខេត្តស្វាយរៀង | ចំនួន ០២ នាក់ | ២៣. សាខាខេត្តព្រះវិហារ | ចំនួន ០១ នាក់ |
| ១១. សាខាខេត្តកំពង់ចាម | ចំនួន ០២ នាក់ | ២៤. សាខាខេត្តរតនគិរី | ចំនួន ០២ នាក់ |
| ១២. សាខាខេត្តកំពង់ធំ | ចំនួន ០២ នាក់ | ២៥. សាខាខេត្តមណ្ឌលគិរី | ចំនួន ០២ នាក់ |
| ១៣. សាខាខេត្តសៀមរាប | ចំនួន ០២ នាក់ | | |

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ រឺបរិញ្ញាបត្ររង ផ្នែកគិលានុបដ្ឋាកឡើងទៅ
- អាចប្រើប្រាស់កម្មវិធី Ms. Word និង Ms. Excel បានល្អ
- ត្រូវមានភាពអំណត់ ស្មោះត្រង់ និងអាចធ្វើការងារជាក្រុម

**៣)- ផ្នែកលេខាធិការ (ស្នាក់ការកណ្តាល) សរុបចំនួន ៧៣ នាក់**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកព័ត៌មានវិទ្យា, អក្សរសាស្ត្រខ្មែរ, រដ្ឋបាលសាធារណៈ, នីតិសាស្ត្រ, សេដ្ឋកិច្ចទូទៅ, គ្រប់គ្រង, គណនេយ្យ, ពាណិជ្ជសាស្ត្រ, គណិតវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល
- អាចប្រើប្រាស់កម្មវិធី Ms. Word, Ms. Excel, អាចសរសេររបាយការណ៍ និងលិខិតរដ្ឋបាលបានល្អ
- មានភាពអំណត់ ស្មោះត្រង់ និងទំនួលខុសត្រូវខ្ពស់

**៤)- ផ្នែកគណនេយ្យ សរុបចំនួន ០២ នាក់**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកគណនេយ្យ, គ្រប់គ្រងហិរញ្ញវត្ថុ ឬសញ្ញាបត្រប្រហាក់ប្រហែល
- អាចប្រើប្រាស់កម្មវិធី Ms. Word និង Ms. Excel បានល្អ
- មានភាពអំណត់ ស្មោះត្រង់ និងទំនួលខុសត្រូវខ្ពស់

**៥)- ផ្នែកព័ត៌មានវិទ្យា សរុបចំនួន ២៦ នាក់**

**៥.១) ផ្នែកអភិវឌ្ឍន៍កម្មវិធី ចំនួន ១០ នាក់**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្ររងផ្នែកព័ត៌មានវិទ្យាឡើងទៅ ឬនិស្សិតដែលកំពុងសិក្សាឆ្នាំទី៣
- មានចំណេះដឹងភាសាអង់គ្លេសជាមូលដ្ឋាន
- មានចំណេះដឹងផ្នែកអភិវឌ្ឍ Web Application (ASP.NET, HTML, CSS, JavaScript)
- មានចំណេះដឹងផ្នែក MVC
- មានចំណេះដឹងផ្នែក Database (MSSQL, MySql)
- មានភាពឧស្សាហ៍ព្យាយាម អាចធ្វើការងារជាក្រុម
- មានការទទួលខុសត្រូវចំពោះការងារ

***ផ្តល់អាទិភាពចំពោះ៖** អ្នកមានចំណេះដឹង Web API, Web Service និងមានបទពិសោធន៍ផ្នែកព័ត៌មានវិទ្យាយ៉ាងតិច០១ឆ្នាំ។

**៥.២)- ផ្នែកតំហែទាំ និងជួសជុលកុំព្យូទ័រ ចំនួន ១៦ នាក់**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្ររងផ្នែកព័ត៌មានវិទ្យាឡើងទៅ ឬនិស្សិតដែលកំពុងសិក្សាឆ្នាំទី៣
- មានចំណេះដឹងផ្នែក តំហែទាំកុំព្យូទ័រ និងជួសជុលកុំព្យូទ័រ
- មានចំណេះដឹងផ្នែកតបណ្តាញ និងដោះស្រាយបញ្ហា Internet និងEmail
- ត្រូវមានភាពអំណត់ ស្មោះត្រង់ អាចធ្វើការជាក្រុម និងទំនួលខុសត្រូវខ្ពស់

**៦)- ផ្នែកប្រចាំការផ្តល់ព័ត៌មាន សរុបចំនួន ១០ នាក់**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រផ្នែកនីតិសាស្ត្រ, សេដ្ឋកិច្ច, គ្រប់គ្រង, ទីផ្សារ ឬសញ្ញាបត្រប្រហាក់ប្រហែល
- អាចនិយាយ និងសរសេរភាសាអង់គ្លេសបានល្អ
- ចេះវិភាគ និងដោះស្រាយបញ្ហា
- អាចប្រើប្រាស់កម្មវិធី Ms. Word និង Ms. Excel បានល្អ
- មានភាពឧស្សាហ៍ព្យាយាម អត់ធ្មត់ និងស្មារតីធ្វើការជាក្រុម
- មានការទទួលខុសត្រូវខ្ពស់ចំពោះការងារ

***ផ្តល់អាទិភាពចំពោះ៖** អ្នកធ្លាប់មានបទពិសោធន៍ការងារផ្នែកផ្តល់ព័ត៌មាន ឬ Call Center។

**៧)- ផ្នែកជាងជួសជុល (អគ្គិសនី-ទឹក)** **សរុបចំនួន ០២ នាក់**

- មានវិញ្ញាបនបត្រក្នុងមុខជំនាញវិជ្ជាជីវៈ
- មានភាពអំណត់ ស្មោះត្រង់ និងទំនួលខុសត្រូវខ្ពស់

**៨)- ផ្នែកអ្នករត់សំបុត្រ** **សរុបចំនួន ០៥ នាក់**

- ត្រូវមានសញ្ញាបត្រចាប់ពីមធ្យមសិក្សាបឋមភូមិឡើងទៅ
- មានភាពអំណត់ ស្មោះត្រង់ និងទំនួលខុសត្រូវខ្ពស់

**២-សំណុំបែបបទដែលត្រូវបំពេញ និងភ្ជាប់មកជាមួយ**

| | |
|---|---|
| ១. ពាក្យសុំប្រឡង | ចំនួន ០១ច្បាប់ |
| ២- តារាងជ្រើសរើសតួនាទី | ចំនួន ០១ច្បាប់ |
| ៣. ប្រវត្តិរូបសង្ខេបមានបិទរូបថត៤x៦ | ចំនួន ០១ច្បាប់ |
| ៤- កិច្ចសន្យាចូលបម្រើការងារ | ចំនួន ០១ច្បាប់ |
| ៥. សេចក្តីចតចម្លងសញ្ញាបត្រដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ច្បាប់ |
| ៦. លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) | ចំនួន ០១ច្បាប់ |
| ៧- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ច្បាប់ |

**កំណត់សម្គាល់៖** *សូមទាញយកពាក្យសុំប្រឡងពីក្នុងគេហទំព័រ ប.ស.ស (Website: www.nssf.gov.kh)*

**៣- មណ្ឌល និងកាលបរិច្ឆេទប្រឡង៖**

- មណ្ឌលប្រឡង, កាលបរិច្ឆេទប្រឡង, ឈ្មោះបេក្ខជន និងការណែនាំផ្សេងៗទាក់ទងនឹងការប្រឡង នឹងផ្សព្វផ្សាយជូនដំណឹងនៅអគារបេឡាជាតិរបបសន្តិសុខសង្គម និងនៅក្នុងគេហទំព័រ ប.ស.ស៖ (Website: www.nssf.gov.kh, www.facebook.com/nssfpage នៅពេលក្រោយ ។

ពាក្យសុំប្រឡងដែលបានបំពេញរួច សូមយកមកដាក់នៅការិយាល័យរដ្ឋបាល ប.ស.ស **(ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ (លើកលែងថ្ងៃបុណ្យ) ពេលព្រឹក៖ ម៉ោង០៨:៣០ ដល់ម៉ោង១១:៣០ និងពេលរសៀល៖ ម៉ោង១៣:៣០ ដល់ម៉ោង១៦:៣០)។**

អាសយដ្ឋាន៖ បេឡាជាតិរបបសន្តិសុខសង្គម អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ **កាលបរិច្ឆេទឈប់ទទួលពាក្យ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៦:០០នាទីរសៀល។**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ៖ ០១២ ២៥៩ ០១៤/០៦៩ ៣៤៣ ៤៧៥/០១០ ២៧០ ៧៦៥។

ថ្ងៃ ច័ន្ទ ៤ កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក សមវិទ្យា**